វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ធនាគារ ANZ Royal

# សង្ខេបចក្ខុវិស័យប្រទេសកម្ពុជា*

ឆ្នាំ ២០១០ លេខ ០៤

## ការពង្រឹងវិស័យសំខាន់ៗដើម្បីសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ឡើងវិញ ការអភិវឌ្ឍប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា៖ ថាមពល និងហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក[១]

"ហេដ្ឋារចនាសម្ព័ន្ធ ជាមូលដ្ឋាននៃការអភិវឌ្ឍទៅអនាគតនៅកម្ពុជា ។"

*លោក David Kerr អគ្គនាយក ក្រុមហ៊ុន Toll កម្ពុជា*

"បញ្ហាប្រឈមសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី រួមមាន ការអនុវត្តឱ្យទាន់ពេលនូវផែនការអភិវឌ្ឍន៍ឆ្នាំ២០១០-២០១៣ ការស្វែងរកមូលនិធិមានលក្ខខណ្ឌសម្បទានថែមទៀត សម្រាប់ការពង្រីកខ្សែបញ្ជូន និងចែកចាយ ការបង្កើនសមត្ថភាពបណ្តាញអគ្គិសនីនៅទូទាំងប្រទេស ដើម្បីស្រូបយកអគ្គិសនីផ្គត់ផ្គង់ និងការដាក់អនុវត្តវិធានការគ្រប់គ្រងហានិភ័យ ។"

*ឯកឧត្តម ហាវ រតនៈ មន្ត្រីត្រួតពិនិត្យរដ្ឋអមអគ្គិសនីកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរងនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ*

### ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី៖ អគ្គិសនីកម្ពុជានាពេលបច្ចុប្បន្ន

គិតមកដល់បច្ចុប្បន្ន អគ្គិសនីកម្ពុជា (EDC) ដែលជាក្រុមហ៊ុនរដ្ឋទទួលបន្ទុកលើការផលិត បញ្ជូន និងចែកចាយអគ្គិសនីនៅកម្ពុជា បានដំណើរការអស់ជាងបួនទសវត្សរ៍មកហើយ ។ សមត្ថភាពបរិក្ខារដែលដាក់ដំឡើង បានកើនឡើងជាលំដាប់ដល់ ៥១៦ មេហ្គាវ៉ាត់ (MW) នៅឆ្នាំ២០០៩ ធៀបនឹង ៣៨៦ MW នៅឆ្នាំ២០០៧ ។ ក្នុងពេលជាមួយគ្នា ផលិតកម្មអតិបរមាជាមធ្យមមានកំរិត៩០%នៃសមត្ថភាពដាក់ដំឡើង ។ ផលិតកម្មថាមពលក្នុងស្រុកសរុប កើនឡើងប្រហែល ២៥% ដល់ ១៨១៨ ហ្គីហ្គាវ៉ាត់ម៉ោង (GWh) (ក្រាហ្វិក ១) ។

ថាមពលផ្គត់ផ្គង់ដោយ EDC មួយភាគធំ បានមកពីផលិតករអគ្គិសនីឯករាជ្យ (IPPs) ប៉ុន្តែការចូលរួមពីប្រភពនេះ កំពុងថយចុះ ដោយវាមានចំណែកប្រមាណ ៥០% នៃបរិមាណសរុបនៅឆ្នាំ២០០៩ ធៀបនឹង ៧៥% នៅឆ្នាំ២០០៧ ។ ក្នុងពេលជាមួយគ្នា ថាមពលនាំចូល ជាពិសេសពីប្រទេសវៀតណាម បានក្លាយទៅជាប្រភពអគ្គិសនីដ៏ចំបងមួយរបស់ EDC ។ ដោយសារថាមពលផលិតដោយ EDC បានធ្លាក់ចុះ ហេតុនេះ ថាមពលនាំចូលបានកើនឡើងពី ៦៩ GWh ដល់ ៧០៥ GWh នៅរវាងឆ្នាំ២០០៧ និង ២០០៩ ហើយចំណែកនៃថាមពលនាំចូលនៅក្នុងថាមពលផ្គត់ផ្គង់សរុប កើនឡើងពី ៥% មកដល់ ៣៩% ។ ទាក់ទងនឹងប្រភពប្រេងឥន្ធនៈ ការផ្គត់ផ្គង់ថាមពលសរុបនៅក្នុងប្រទេសភាគច្រើន ត្រូវបានផលិតនៅក្នុងស្រុកដោយប្រើម៉ាស៊ូតធ្ងន់ (Heavy Fuel Oil) ប៉ុន្តែការផ្គត់ផ្គង់ប្រភេទនេះ បានធ្លាក់ចុះពី ៨៥% ក្នុងឆ្នាំ២០០៧ មកត្រឹម ៥៤% ក្នុងឆ្នាំ២០០៩ ។ អគ្គិសនីផលិតក្នុងស្រុកដោយប្រើប្រេងម៉ាស៊ូត មានកម្រិតទាប និងបានថយចុះដូចគ្នា ពី ៧% មកត្រឹម ២% នៃអគ្គិសនី

ក្រាហ្វិក ១៖ ផលិតកម្មអគ្គិសនីរបស់ EDC តាមប្រភព គិតជា GWh




ប្រភព៖ EDC

១ សង្ខេបចក្ខុវិស័យលេខ ៤ ជាការបូកសរុបបទបង្ហាញ និងការពិភាក្សាផ្សេងៗ នៅវគ្គទី ៣ខ (i) នៃសន្និសីទស្តីពីចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១០ ។ វាគ្មិនក្នុងវគ្គនេះ មានដូចតទៅ៖ ឯកឧត្តម ហាវ រតនៈ ជាមន្ត្រីត្រួតពិនិត្យរដ្ឋអម EDC និងលោក David Kerr អគ្គនាយកក្រុមហ៊ុន Toll កម្ពុជា ។ អត្ថបទសង្ខេបនេះ ក៏មានបញ្ចូលផ្នែកទាក់ទងមួយចំនួន ដែលជាបទបង្ហាញរបស់បណ្ឌិត ហង់ ជួន ណារ៉ុន នៅវគ្គទី ១ ។

* ផ្អែកលើសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០១០:
ភាពជាដៃគូរវាងវិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal

ផ្គត់ផ្គង់សរុប ។ ប៉ុន្តែការធ្លាក់ចុះទាំងនេះ ត្រូវបានប៉ះប៉ូវមកវិញ ដោយសារអគ្គិសនីនាំចូលដែលកើនឡើង ។ វារីអគ្គិសនី នៅតែជាប្រភពថាមពលដ៏តូចមួយ ដោយបានចូលរួមចំណែក ៣% ក្នុងរយៈពេលបីឆ្នាំកន្លងទៅនេះ ។

នៅកម្ពុជា អគ្គិសនីថ្លៃខ្លាំងណាស់ ។ ចំណាយផលិតកម្មនៅភ្នំពេញឡើងដល់ ០,១៨ដុល្លារអាមេរិកក្នុងមួយគីឡូវ៉ាត់ម៉ោង (kWh) ក្នុងនេះមាន ០,១២ដុល្លារអាមេរិកជាចំណាយផលិតកម្ម ហើយចំណែកនៅសល់ គឺជាចំណាយសេវាកម្ម ។ ទោះមានឧបត្ថម្ភធនពីរដ្ឋាភិបាលក្តី ក៏ថ្លៃលក់អគ្គិសនីនៅតែមានកម្រិតខ្ពស់ខ្លាំងដដែល ។ សំរាប់និវាសជននៅភ្នំពេញ ថ្លៃលក់មានឧបត្ថម្ភធនគឺ ៦១០រៀល/kWh សម្រាប់ការប្រើប្រាស់ត្រឹម ៥0kWh ក្នុងមួយខែ និង ៧២០រៀលសម្រាប់ការប្រើប្រាស់ត្រឹម ១០០kWh ។ ថ្លៃលក់សម្រាប់ការប្រើប្រាស់លក្ខណៈពាណិជ្ជកម្ម និងឧស្សាហកម្ម ប្រែប្រួលខុសៗគ្នា ។ គេត្រូវបូកបន្ថែមទៅលើចំណាយមធ្យមនៃផលិតកម្មចម្រុះ នូវការគិតថ្លៃដូចតទៅ៖ ១១៤រៀល/kWh សម្រាប់អតិថិជនប្រើប្រាស់តិច ១១២រៀល/kWh សម្រាប់អតិថិជនប្រើប្រាស់មធ្យម និង ៩៦រៀល/kWh សម្រាប់អតិថិជនប្រើប្រាស់ច្រើន ។ដោយសារប្រេងឥន្ធនៈ និងថាមពលនាំចូលមានតម្លៃទាបជាងមុន ហេតុនេះ ថ្លៃអគ្គិសនីក្នុងឆ្នាំ២០០៩ មានកម្រិតថោកជាងឆ្នាំ២០០៨ ។

កំណើនអតិថិជន និងការថយចុះ ការបាត់បង់ថាមពល បានបង្កើនបរិមាណលក់ ១០០% នៅចន្លោះឆ្នាំ ២០០៥ និង ២០០៩ ។ បើគិតជាភាគរយនៃផលិតកម្មសរុប អគ្គិសនីលក់បានសរុបកើនបានប្រហែល ២ឯកតាភាគរយ (2 percentage points) ។ ក្នុងពេលជាមួយគ្នា ចំនួនអ្នកប្រើប្រាស់របស់ EDC កើនឡើងជាង ៥០% ដោយសារកំណើនអ្នកប្រើប្រាស់អគ្គិសនីជានិវាសជន និងជាសហគ្រាសពាណិជ្ជកម្ម ។ ទន្ទឹមគ្នានោះ ការបាត់បង់ថាមពលអាចទប់ស្កាត់បានដោយជោគជ័យ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅ ។ ការបាត់បង់ថាមពលផលិតបាននៅឆ្នាំ២០០០ មានកម្រិតខ្ពស់ដល់ ១៦% នៃថាមពលផលិតសរុប ។ ប៉ុន្តែវាថយចុះជាលំដាប់មកត្រឹម ១២% នៅឆ្នាំ២០០៥ និង ១០% នៅឆ្នាំ២០០៩ (ក្រាហ្វិក ២) ។

កំណែទម្រង់ក្នុងសេវាកម្មអតិថិជន និងការអភិវឌ្ឍធនធានមនុស្ស បានជួយពង្រីកមូលដ្ឋានអតិថិជន និងលើកកម្ពស់ប្រសិទ្ធភាពប្រតិបត្តិការរបស់ EDC ។ ខ្សែទូរស័ព្ទទំនាក់ទំនង ២៤ម៉ោង បានដាក់ដំឡើងនៅតាមប្រព័ន្ធទាំងអស់របស់ EDC នៅឆ្នាំ២០០៩ ។ នៅឆ្នាំដដែល គេអាចធ្វើការទូទាត់បែបអេឡិចត្រូនិក តាមម៉ាស៊ីន ATM និងអ៊ីនធឺណិតនូវវិក្កយប័ត្រអគ្គិសនីបាន ។ ការអភិវឌ្ឍធនធានមនុស្សរបស់ EDC គឺមានទាំងការបន្ថែមបុគ្គលិក និងការកសាងសមត្ថភាព ។ ចំនួនបុគ្គលិករបស់ EDC បានកើន ៧% នៅឆ្នាំ២០០៩ បើធៀបនឹងឆ្នាំ២០០៧ ។ ក្រុមហ៊ុនក៏បានបញ្ជូនមន្ត្រីជាច្រើនទៅបរទេស ដើម្បីសិក្សា និងទទួលការ

ក្រាហ្វិក ២៖ បំរែបំរួលជាភាគរយនៃការលក់ថាមពល ចំនួនអតិថិជន និងការបាត់បង់ថាមពលផលិតបាន របស់ EDC ក្នុងឆ្នាំ២០០៩ ធៀបនឹងឆ្នាំ២០០៥




ប្រភព៖ EDC

បណ្តុះបណ្តាលបន្ថែម ព្រមទាំងបានឱ្យបុគ្គលិករបស់ខ្លួនចូលរៀននៅតាមសាកលវិទ្យាល័យនៅកម្ពុជា ដើម្បីបំពេញការសិក្សាកម្រិតបរិញ្ញាបត្រ ។

## ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី៖ អនាគតរបស់ EDC

រដ្ឋាភិបាល មានទិសដៅកែលំអបណ្តាញអគ្គិសនីនៅក្នុងប្រទេស ជាពិសេសនៅតាមតំបន់ជនបទ ។ ទិសដៅនេះសំខាន់បំផុត ដើម្បីអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជាឲ្យបានសំរេច ។ ដើម្បីបំពេញទិសដៅនេះ រដ្ឋាភិបាលមានគោលដៅអភិវឌ្ឍន៍វិស័យថាមពលសំខាន់ពីរ សម្រាប់ឆ្នាំ ២០០៩-២០១៣ គឺការកាត់បន្ថយបន្ទុកចំណាយផលិតកម្ម និងការបង្កើនវិសាលភាពនៃការផ្គត់ផ្គង់ ដែលត្រូវសំរេចឲ្យបាន ដោយប្រើយុទ្ធសាស្ត្រដូចតទៅ៖ ការបង្កើនការនាំចូលថាមពលពីប្រទេសជិតខាង ការសាងសង់និងធ្វើប្រតិបត្តិការប្រភពអគ្គិសនីសំខាន់ៗ ការតភ្ជាប់តំបន់ទីក្រុងសំខាន់ៗទៅនឹងបណ្តាញអគ្គិសនីទូទាំងប្រទេស និងការកសាងខ្សែបញ្ជូន និងចែកចាយនៅទូទាំងប្រទេស ។ ផ្អែកលើផែនការគោលរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងខេត្តទាំង ២៣ របស់កម្ពុជា នឹងត្រូវតភ្ជាប់ទៅនឹងបណ្តាញអគ្គិសនីទូទាំងប្រទេសនៅត្រឹមឆ្នាំ២០១៨។ផ្អែកលើផែនការអភិវឌ្ឍន៍បណ្តាញអគ្គិសនីទូទាំងប្រទេសឆ្នាំ ២០០៩-២០១៣ បណ្តាញតភ្ជាប់អគ្គិសនីពីប្រទេសវៀតណាមមករាជធានីភ្នំពេញ និងពីរាជធានីភ្នំពេញទៅកាន់ខេត្តនានានៅកម្ពុជា ត្រូវបានសាងសង់រួចហើយ ។

ការផលិតថាមពលសរុប រំពឹងថានឹងបន្តកើនឡើង ហើយពីឆ្នាំ២០១០ ដល់ ២០១៥ រំពឹងថានឹងកើនពី ២០០០ MW ដល់ជាង ៤៥០០ MW (ក្រាហ្វិក ៣) ។ ផ្អែកតាមផែនការអភិវឌ្ឍន៍បណ្តាញអគ្គិសនីទូទាំងប្រទេសឆ្នាំ២០០៩-២០១៣ អគ្គិសនីប្រមាណ ២០០ MW នឹងត្រូវនាំចូលពីប្រទេសវៀតណាមជារៀងរាល់ឆ្នាំពីឆ្នាំ២០១០ដល់២០១៣។ អគ្គិសនីនាំចូលពីប្រទេសថៃ មានប្រមាណ ៦០ MW នៅឆ្នាំ ២០១២ និង ២០១៣ ។ទាក់ទងនឹងប្រភេទឥន្ធនៈគេប្រមើលឃើញថា វារីអគ្គិសនីនឹងក្លាយជាប្រភពអគ្គិសនីដ៏សំខាន់នៅ

ក្រាហ្វិក ៣ ៖ ការព្យាករណ៍ពីផលិតកម្មអគ្គិសនីរបស់EDCគិតជាGWh




ប្រភព ៖ EDC

ឆ្នាំ២០១៥ ដោយជួយកាត់បន្ថយតម្រូវការអគ្គិសនីនាំចូល និងអគ្គិសនីផលិតដោយម៉ាស៊ូតធ្ងន់ (Heavy Fuel Oil) ។ ការផលិតអគ្គិសនីដោយប្រើធ្យូងថ្ម ក៏រំពឹងថា នឹងកាន់តែពង្រីកបន្ថែមដែរ ។ កិច្ចសន្យាជាមួយ IPPs ភាគច្រើន នឹងត្រូវបញ្ចប់អស់នៅឆ្នាំ២០១៣ ហើយការផ្គត់ផ្គង់អគ្គិសនីដែលនៅមានសុពលភាព នឹងត្រូវកំណត់ថ្លៃត្រឹមកម្រិតអប្បបរមា ។

វិនិយោគក្នុងការផលិតអគ្គិសនី រំពឹងថានឹងពឹងផ្អែកជាសំខាន់លើហិរញ្ញប្បទានពីវិស័យឯកជន តាមរយៈយន្តការសាងសង់-អាជីវកម្ម-ផ្ទេរ (build-operate-transfer: BOT) ។ សម្រាប់ឆ្នាំ២០០៩-២០១៣ វិនិយោគបែបនេះ រំពឹងថាមានតម្លៃដល់ជាង ១,៩ពាន់លានដុល្លារអាមេរិក ដែលបានពីវិស័យឯកជន និងម្ចាស់ជំនួយ ហើយផ្តល់នូវសមត្ថភាពដាក់ដំឡើងចំនួន ១.៣២០MW និងសមត្ថភាពប្រើការបាន ១.០៧០ MW ។ វិនិយោគលើបណ្តាញអគ្គិសនីទូទាំងប្រទេស រំពឹងថានឹងទទួលបានហិរញ្ញប្បទានមួយផ្នែកតាមរបៀប BOT និងមួយផ្នែកតាមការផ្តល់ហិរញ្ញប្បទានពីធនាគារបរទេស ។ សម្រាប់ឆ្នាំ២០០៩-២០១៣ វិនិយោគដូចលើកឡើងនេះ គ្រោងមានដល់ ៥៧០លានដុល្លារអាមេរិក ។ ម៉្យាងទៀត ម្ចាស់ជំនួយនិងកម្ចីធនាគារឯកជន រំពឹងថានឹងផ្តល់ហិរញ្ញប្បទានសំរាប់ការពង្រីកហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីនៅតំបន់ជនបទ ។ នាបច្ចុប្បន្ន ស្ថាប័នដែលកំពុងចូលរួមក្នុងគំនិតផ្តួចផ្តើមនេះ រួមមាន ទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ (AusAID) ធនាគារពិភពលោក (World Bank) ធនាគារ KfW និង ធនាគារ China EXIM ។

អគ្គិសនីកម្ពុជា នៅមានសកម្មភាពត្រូវធ្វើជាច្រើន ដើម្បីសំរេចគោលដៅរបស់ខ្លួន ។ បញ្ហាប្រឈមសំខាន់ៗ សម្រាប់សហគ្រាសសាធារណៈ មានដូចជា ការអនុវត្តឱ្យបានទាន់ពេលនូវផែនការអភិវឌ្ឍន៍ឆ្នាំ២០១០-២០១៣ ការស្វែងរកមូលនិធិមានលក្ខខណ្ឌសម្បទានថែមទៀត សម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ការកសាងសមត្ថភាពបណ្តាញអគ្គិសនីទូទាំងប្រទេស ដើម្បីស្រូបយកថាមពលផ្គត់ផ្គង់ និងការលើកកម្ពស់ការអនុវត្តរបៀបរបបគ្រប់គ្រងហានិភ័យ ។

សម្រាប់ផ្នែកនីមួយៗ នៃហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី ត្រូវអនុវត្តសកម្មភាពជាអាទិភាពមួយចំនួន ។ ទាក់ទងនឹងការផលិត ការសាងសង់វារីអគ្គិសនី និងរោងចក្រអគ្គិសនីដើរដោយធ្យូងថ្ម ត្រូវអនុវត្តជាបន្ត ។ ត្រូវផ្តល់អាទិភាពដល់គំរោងវិនិយោគមានចំណាយទាប ដែលជួយធ្វើឱ្យចំណាយផលិតកម្មធ្លាក់ចុះ ។ សម្រាប់ការបញ្ជូនអគ្គិសនី ខ្សែបញ្ជូនសំខាន់ៗដែលតភ្ជាប់ពីភ្នំពេញទៅខេត្តនានា ត្រូវតែធ្វើឲ្យរួចរាល់ជាស្រេច ។ គំរោងខ្សែបញ្ជូនជារង្វង់ដែលគ្របដណ្តប់លើរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ និងកណ្តាល នឹងជួយឲ្យតំបន់ទាំងនេះកាន់តែទាក់ទាញខ្លាំងឡើងសម្រាប់សហគ្រាសពាណិជ្ជកម្ម ។ ការសាងសង់មជ្ឈមណ្ឌលបញ្ជូនអគ្គិសនីទូទាំងប្រទេស ក៏ជាអាទិភាពមួយដែរ ។ ទាក់ទិននឹងការចែកចាយ EDC ដូចជាចាំបាច់ត្រូវទទួលចាត់ចែង និងស្តារឡើងវិញនូវប្រព័ន្ធចែកចាយនៅតាមខេត្តមួយចំនួន និងកាត់បន្ថយការដាច់អគ្គិសនី ។ ប្រព័ន្ធចែកចាយនៅរាជធានីភ្នំពេញ ក៏ត្រូវពិនិត្យឡើងវិញដែរ ដើម្បីបង្កើនការយល់ដឹងពីវិធីលើកកម្ពស់គុណភាព និងស្ថិរភាពនៃការផ្គត់ផ្គង់អគ្គិសនី ។ កិច្ចប្រឹងប្រែងសំដៅកាត់បន្ថយការបាត់បង់អគ្គិសនី ត្រូវតែបន្តទៅមុខ និងពង្រឹងបន្ថែម ។ សម្រាប់ EDC ខ្លួនឯង ត្រូវបង្កើនប្រសិទ្ធភាពការងារនៅគ្រប់សាខាទាំងអស់ ដោយសើរើរៀបចំមុខងារឡើងវិញ និងធ្វើកំណែទំរង់សេវាអតិថិជនថែមទៀត ។

## ហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក៖ ស្ថានភាពបច្ចុប្បន្ន

រដ្ឋាភិបាលកម្ពុជា បានចុះកិច្ចសន្យាម៉ៅការប្រតិបត្តិការផ្លូវដែករបស់ខ្លួន ។ នាបច្ចុប្បន្ន រដ្ឋាភិបាលត្រូវពឹងផ្អែកលើម្ចាស់ជំនួយ និងវិស័យឯកជន ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក ដែលមានតំរូវការជាខ្លាំងនៅកម្ពុជា ។ ប្រព័ន្ធដឹកជញ្ជូននៅកម្ពុជា ជាទូទៅមានលក្ខណៈក្មេងខ្ចី ដាច់ដោយដុំ និងទាមទារការស្តាររៀបចំយ៉ាងច្រើន ។ កម្ពុជា ស្ថិតក្នុងចំណោមប្រទេសមានកំណើនលឿនបំផុតនៅអាស៊ី និងកំពុងអនុវត្តកំណែទម្រង់សេដ្ឋកិច្ចសំខាន់ៗ ដើម្បីជំរុញការអភិវឌ្ឍ ។ ស្ថានភាពនេះ បានទាក់ទាញវិស័យឯកជនឲ្យចាប់អារម្មណ៍ធ្វើវិនិយោគទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា ។

នៅឆ្នាំ២០០៩ រដ្ឋាភិបាលបានផ្តល់សម្បទានផ្តាច់មុខរយៈពេល ៣០ឆ្នាំ សម្រាប់ការធ្វើប្រតិបត្តិការអាជីវកម្មលើបណ្តាញផ្លូវដែកកម្ពុជា ទៅឱ្យក្រុមហ៊ុនផ្លូវដែក Toll Royal Railway ដែលជាក្រុមហ៊ុនចម្រុះរវាងក្រុមហ៊ុនអូស្ត្រាលី Toll Holdings និងក្រុមហ៊ុនកម្ពុជា Royal Group ។ ទន្ទឹមនោះ ADB និង AusAID បានផ្តល់មូលនិធិសំរាប់ការស្តារហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកឡើងវិញ ជាពិសេសខ្សែផ្លូវដែកដូចតទៅ៖ ខ្សែខាងត្បូងប្រវែង ២៥៤គីឡូម៉ែត្រ តភ្ជាប់ពីភ្នំពេញទៅកំពង់ផែខេត្តព្រះសីហនុ ខ្សែខាងជើងប្រវែង៣៤០គីឡូម៉ែត្រ ពីភ្នំពេញទៅសិរីសោភ័ណនិងកំណាត់បាត់ផ្លូវដែកប្រវែង៤៨គីឡូម៉ែត្រពីសិរីសោភ័ណទៅប៉ោយប៉ែត ។ មូលនិធិមួយចំនួន ក៏បានបែងចែកទុកសាងសង់ចំណតថ្មី សម្រាប់ផ្ទុកទំនិញដឹកតាមមធ្យោបាយច្រើនបែបនៅជាយក្រុងភ្នំពេញ ។

ម្ចាស់ជំនួយជាអ្នកផ្តល់ហិរញ្ញប្បទានសំរាប់ការស្តារផ្លូវដែកឡើងវិញ ហើយសម្បទានិកត្រូវថែទាំហេដ្ឋារចនាសម្ព័ន្ធ និងបើកដំណើរការរថភ្លើង ។ Toll Royal Railway គ្រោងបង្កើតជាវិធីដឹកជញ្ជូនឆ្លងកាត់តំបន់មេគង្គ ហើយដឹងច្បាស់ថា កម្ពុជា និងបណ្តាញផ្លូវដែកនៅកម្ពុជា មានសារៈសំខាន់បំផុតសម្រាប់គំរោងផ្លូវដែកសិង្ហបូរី-គុនមីញ ។ទិសដៅសំខាន់គឺរចនារៀបចំ និងដំណើរការអាជីវកម្មដឹកជញ្ជូនទំនិញតាមផ្លូវដែកមួយដែលសមស្រប មានសុវត្ថិភាពល្អ ជួយសន្សំសំចៃ និងអាចបត់បែនបាន ហើយមានសមត្ថភាពអាចផ្តល់ទុនដោយខ្លួនឯងក្នុងរយៈពេលមធ្យម ទៅរយៈពេលវែង ។ គេមានទំនុកចិត្តខ្ពស់ថា គំរោងនេះ អាចអនុវត្តបានសំរេចតាមពេលវេលា និងថវិកាគ្រោងទុក ។ រថភ្លើងទីមួយ នឹងចាប់ដំណើរការរត់លើខ្សែផ្លូវដែកជួសជុលថ្មី នៅត្រីមាសទី៤ ឆ្នាំ២០១០ ។ គោលដៅមួយទៀត គឺការបង្កើតការតភ្ជាប់ផ្លូវដែក កំពង់ផែ និងចំណតផ្ទុកទំនិញ ដឹកតាមមធ្យោបាយច្រើនបែប ដើម្បីមានខ្សែរយៈផ្គត់ផ្គង់ភ័ស្តុភារដ៏រលូនមួយ ។ ការងារនេះ នឹងជួយកាត់បន្ថយចំណាយរបស់រដ្ឋាភិបាលលើការសាងសង់ផ្លូវថ្នល់ ។ គោលដៅមួយផ្សេងទៀត គឺការបើកដំណើរការតំបន់ពាណិជ្ជកម្មឆ្លងកាត់ព្រំដែនសេរី ដែលជួយឱ្យកុងតឺនឺអាចដឹកបានលឿនប្រកបដោយសុវត្ថិភាព និងសន្សំសំចៃ រវាងប្រទេសជាច្រើននៅអាស៊ី ។

## ហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក ៖ តម្រូវការរបស់វិស័យឯកជន

តម្រូវការមួយចំនួនគួរតែដោះស្រាយឲ្យបាន ដើម្បីឱ្យការចូលរួមរបស់វិស័យឯកជន ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកអាចទទួលបានជោគជ័យ ។តម្រូវការធំបំផុតគឺផ្លូវដែកត្រូវចូលដល់កំពង់ផែផ្ទាល់ ។ រដ្ឋាភិបាលត្រូវយល់ព្រមឲ្យមានផ្លូវដែក ចូលទៅដល់ចំណតដាក់កុងតឺនឺនៅកំពង់ផែក្រុងព្រះសីហនុ ។ តម្រូវការមួយទៀត គឺការដាក់អនុវត្តនូវស្តង់ដារសាយភាយប្រភេទទី ២ (Tier 2 emission standards) ក្រោម ISO 8178 ។ ម្យ៉ាងទៀត វិស័យឯកជន ក៏ត្រូវការទូទាត់ពន្ធគយដែលមានប្រសិទ្ធភាព និងឆាប់រហ័ស ។ កុងតឺនឺត្រូវអាចដឹកជញ្ជូនតាមផ្លូវដែក ក្រោមត្រាបញ្ជាក់ពីគយបាន (under-bond) ។ សម្រាប់ប្រតិបត្តិករដឹកជញ្ជូនតាមផ្លូវថ្នល់ គួរពិចារណាធ្វើការចុះបញ្ជីយានយន្ត ដោយផ្អែកលើមូលដ្ឋាន "អ្នកប្រើប្រាស់ត្រូវទូទាត់បង់" ។ ឧបត្ថម្ភធនលើប្រេងឥន្ធនៈសម្រាប់សម្បទានិក ក៏ជាសំណើមួយដែរ ។ សព្វថ្ងៃ ក៏ត្រូវមានប្រព័ន្ធច្បាប់ដ៏រឹងមាំមួយដែរ ។ វិធានស្តីពីការចុះបញ្ជីរថយន្តកាមីញ៉ុងធំៗ និងការសាយភាយប្រេងឥន្ធនៈ ក៏ត្រូវកំណត់ឱ្យបានច្បាស់លាស់ ។ម្យ៉ាងទៀតត្រូវដាក់អនុវត្តស្តង់ដារសុវត្ថិភាពផ្លូវដ៏តឹងរ៉ឹង និងត្រូវធ្វើការត្រួតពិនិត្យ និងពង្រឹងអនុវត្ត ។ ត្រូវអនុម័តប្រើស្តង់ដារអន្តរជាតិ សម្រាប់លក្ខណៈអាចបើកបរយានយន្តលើផ្លូវបាន ។ រាល់ប្រតិបត្តិការដែលមិនស្របច្បាប់ត្រូវតែបញ្ឈប់ ។ ទាក់ទងនឹងការយកពន្ធ និងបែបបទគយលើទំនិញដឹកតាមផ្លូវដែកឆ្លងកាត់ព្រំដែន ត្រូវមានកិច្ចព្រមព្រៀងជាមួយប្រទេសជិតខាង ដែលត្រូវការចរចាគ្នាតាំងពីពេលនេះដែរ ។ សម្រាប់ទំនាក់ទំនងសាធារណៈ រដ្ឋាភិបាលត្រូវពាក់ព័ន្ធជាមួយសាធារណជនតាមក្រុមផ្សេងៗ ជាពិសេសក្រុមនានាដែលនឹងទទួលផលប៉ះពាល់ផ្ទាល់ ដើម្បីស្វែងយល់ពីផលចំណេញនៃគំរោងផ្លូវដែក ។ ក្នុងស្ថានភាពបច្ចុប្បន្ន កិច្ចសន្យាសម្បទានជាមួយក្រុមហ៊ុន Toll Royal Railway ផ្តោតទៅលើការដឹកជញ្ជូនតាមផ្លូវដែក មិនមែនអ្នកដំណើរទេ ។ ដូច្នេះ ត្រូវមានកិច្ចសន្យាមួយលើសេវាកម្មដឹកអ្នកដំណើរ ។

ការអភិវឌ្ឍធនធានមនុស្ស ជាកត្តាសំខាន់បំផុត ។ ការបណ្តុះបណ្តាល ផ្អែកលើសមត្ថភាពអភិវឌ្ឍ ត្រូវមានផ្តល់ឱ្យ ដូចជា ការបណ្តុះបណ្តាលជំរុញឱ្យមានការប្រតិបត្តិតាមរបៀបរបបអនុវត្តល្អខាងបរិស្ថានជាដើម ។ សុវត្ថិភាពពលករ ក៏ជាអាទិភាពមួយដែរ ។ វិធានទាក់ទងនឹងបទបញ្ញត្តិ និងការប្រើប្រាស់សម្ភារៈការពារបុគ្គល ក៏ត្រូវមានការណែនាំបង្ហាញ ដាក់អនុវត្ត និងពង្រឹងអនុវត្ត ក្នុងពេលជាមួយគ្នានោះ ក៏ត្រូវមានការពិនិត្យសុខភាពមុនពេលឲ្យចូលធ្វើការ និងតាមពេលកំណត់ ដើម្បីពិនិត្យពីស្ថានភាពសុខភាពរបស់កម្មករនិយោជិត ។

សម្រាប់រថភ្លើងដែលដាក់ប្រើប្រាស់ និងដំណើរការប្រកបដោយប្រសិទ្ធភាព វាអាចជំនួសឱ្យការដឹកជញ្ជូនតាមផ្លូវថ្នល់តាមរថយន្តកាមីញ៉ុងធំៗចំនួន១០០ជើង ។ទូរថភ្លើងនីមួយៗ អាចដឹកទំនិញបាន ៦៤តោន តាមខ្សែផ្លូវដែកខាងត្បូង និង ៤៤តោន តាមខ្សែខាងជើង ។ ដូច្នេះ ការអភិវឌ្ឍផ្លូវដែកនៅកម្ពុជា ផ្តល់ផលចំណេញយ៉ាងសំខាន់ និងធំធេងណាស់ ។នៅពេលនេះ រដ្ឋាភិបាលបានផ្ទេរបន្ទុកនៃការអភិវឌ្ឍផ្លូវដែកទៅឱ្យវិស័យឯកជនរួចហើយ ប៉ុន្តែនៅមានកិច្ចការត្រូវដោះស្រាយនូវបញ្ហាខាងគោលនយោបាយផ្សេងៗ ដែលរារាំងវិស័យឯកជនក្នុងការអនុវត្តចំណែកការងាររបស់គេ និងម្ចាស់ជំនួយ ក្នុងការមើលឃើញពីផ្លែផ្កានៃជំនួយហិរញ្ញវត្ថុរបស់គេដែរ ។ រដ្ឋាភិបាលកម្ពុជាត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីដោះស្រាយបញ្ហាគោលនយោបាយ នៅពេលនេះតែម្តង បើពុំនោះទេ ធនាគារអភិវឌ្ឍន៍អាស៊ី AusAID និងវិស័យឯកជននឹងត្រូវចំណាយអស់ជាង ២០០លានដុល្លារ ដើម្បីស្តារកសាងឡើងវិញនូវបណ្តាញផ្លូវដែកមួយ ដែលមិនអាចធ្វើអាជីវកម្មដឹកជញ្ជូនទំនិញឲ្យរស់រាន និងមានចីរភាពជាលក្ខណៈពាណិជ្ជកម្មបាន ។ ដូច្នេះ ត្រូវចាត់វិធានការជាបន្ទាន់ ។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI)**
☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា ✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☏ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨ (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@wicam.com.kh, website: http://www.cdri.org.kh